ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

ការិយាល័យអ្នកនាំពាក្យ

លេខ ៣២៣ សប្រក

# សេចក្តីប្រកាសពត៌មាន

## ស្តីពីសម័យប្រជុំពេញអង្គរបស់គណៈរដ្ឋមន្ត្រី

## ថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០០៥

ថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០០៥ វេលាម៉ោង ៨:៣០ នាទី នៅទីស្តីការគណៈរដ្ឋមន្ត្រី មានបើកសម័យប្រជុំពេញអង្គរបស់គណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់ សម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ដើម្បីឆ្លង :

**១~សេចក្តីព្រាងវិសោធនកម្មច្បាប់ ស្តីពីសភាពាណិជ្ជកម្ម**

**២~បញ្ហាផ្សេងៗ :** សំណើសុំការយល់ព្រមពីគណៈរដ្ឋមន្ត្រី ដើម្បីសុំការអនុម័តពីរដ្ឋសភា និងព្រឹទ្ធសភា លើអនុសញ្ញា ស្តីពីការការពារបេតិកភ័ណ្ឌវប្បធម៌អរូបី

ក្រោយពីបានពិភាក្សានិងផ្លាស់ប្តូរយោបល់រួចមក អង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីបានសំរេចឯកភាព :

### I~លើសេចក្តីព្រាងវិសោធនកម្មច្បាប់ ស្តីពីសភាពាណិជ្ជកម្ម

សេចក្តីព្រាងវិសោធនកម្មច្បាប់ ស្តីពីសភាពាណិជ្ជកម្មនេះ ត្រូវបានរៀបចំឡើងដោយក្រសួងពាណិជ្ជកម្ម ក្នុងគោលបំណងឈានទៅបង្កើតសភាពាណិជ្ជកម្មថ្នាក់ជាតិមួយដោយប្រមូលផ្តុំសភាពាណិជ្ជកម្មខេត្ត-ក្រុងទាំងអស់ និងម្យ៉ាងទៀតក្នុងគោលបំណងជួយឧបត្ថម្ភថវិកាខ្លះដល់សភាពាណិជ្ជកម្មខេត្ត-ក្រុងទើបបង្កើតថ្មី ។ នៅក្នុងមាត្រាទី ២ ថ្មី នៃសេចក្តីព្រាងច្បាប់នេះ បានចែងថា : សភាពាណិជ្ជកម្មនៅតាមខេត្ត-ក្រុងនីមួយៗ និងការកំណត់ព្រំដែនមណ្ឌលនៃសភាពាណិជ្ជកម្មនៃខេត្ត-ក្រុងនីមួយៗនេះ ត្រូវបង្កើតឡើងដោយអនុក្រឹត្យតាមសំណើរបស់ក្រសួងពាណិជ្ជកម្ម ។ ព្រំដែនមណ្ឌលនៃសភាពាណិជ្ជកម្មនីមួយៗ ត្រូវកំណត់ឡើងដោយអនុក្រឹត្យដែលបង្កើតសភានេះ ។ សភាពាណិជ្ជកម្មទាំងនោះ ត្រូវប្រមូលផ្តុំគ្នាបង្កើតជាសភាពាណិជ្ជកម្មថ្នាក់ជាតិមួយហៅថា សភាពាណិជ្ជកម្មកម្ពុជា ដែលធ្វើសកម្មភាពទូទាំងព្រះរាជាណាចក្រកម្ពុជា ។ ការរៀបចំ និងការប្រព្រឹត្តទៅ ព្រមទាំងភារកិច្ចរបស់សភាពាណិជ្ជកម្មកម្ពុជានឹងត្រូវកំណត់ដោយអនុក្រឹត្យ ស្តីពីសភាពាណិជ្ជកម្មកម្ពុជា តាមសំណើរបស់ក្រសួងពាណិជ្ជកម្ម ។ ទាក់ទងទៅនឹងការជួយឧបត្ថម្ភថវិកាដល់សភាពាណិជ្ជកម្មនេះ ដែលមានចែងនៅក្នុងមាត្រាទី ១៥ ថ្មី អង្គប្រជុំគណៈរដ្ឋមន្ត្រី បានឯកភាពតាមក្រសួងសាមីដោយដាក់ថា ការចំណាយសំរាប់ការប្រព្រឹត្តិទៅនៃសភាពាណិជ្ជកម្មត្រូវ

ផ្តត់ផ្គង់ដោយ : វិភាគទាន របស់សមាជិក, អំណោយក្នុងនិង ក្រៅប្រទេស, ចំណូលមកពីការគ្រប់គ្រងគ្រឹះស្ថាន និងការដេញថ្លៃនានា, វិភាគទានបានមក ពីប្រភេទផ្សេងៗ ក្នុងនោះចំណែកខ្លះ បានមកពីការចុះបញ្ជីពាណិជ្ជកម្ម ។

ការបង្កើតសភាពាណិជ្ជកម្មថ្នាក់ជាតិ ផ្តល់អត្ថប្រយោជន៏ដូចជា ១-ពង្រីកសហប្រតិបត្តិការសភាពាណិជ្ជកម្ម ខេត្ត-ក្រុងជាមួយបរទេសបានតាមរយៈ សភាពាណិជ្ជកម្មថ្នាក់ជាតិ, ២-ប្រមូលទុនកាន់តែទូលាយ របស់វិស័យឯកជន, ៣-បង្កលក្ខណៈអោយវិស័យឯកជន ដឹកនាំវិស័យឯកជនដោយខ្លួនឯង, ៤-សហការជាដៃគូរដ៏ល្អជាមួយរាជរដ្ឋាភិបាល អនុវត្តគោលនយោបាយអភិវឌ្ឍន៏សេដ្ឋកិច្ចជាតិ អោយបានស៊ីសង្វាក់គ្នានៅទូទាំងប្រទេស, ៥-បំពេញកិច្ចការទាំងឡាយក្រៅពីភារកិច្ចរបស់សភាពាណិជ្ជកម្មខេត្ត-ក្រុង និង ៦-បង្រួបបង្រួមសភាពាណិជ្ជកម្មខេត្តក្រុង អោយធ្វើសហប្រតិបត្តិការគ្នា ដើម្បីប្រើប្រាស់សក្តានុពលដែលមាននៅតាមខេត្ត-ក្រុងនីមួយៗ ។

## II-អំពីបញ្ហាផ្សេងៗ

គណៈរដ្ឋមន្ត្រីបានឯកភាពលើអនុសញ្ញាស្តីពីការ ការពារបេតិកភ័ណ្ឌអរូបីដោយបញ្ជូនទៅស្ថាប័ននីតិបញ្ញត្តិដើម្បីសុំសច្ចាប័ន ។

អង្គប្រជុំគណៈរដ្ឋមន្ត្រីបានបិទសម័យប្រជុំនៅម៉ោង ១០ និង ៣០ នាទី ។

ភ្នំពេញ, ថ្ងៃទី ១៩ ខែ សីហា ២០០៥